**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុប្បយោគ និងផ្ទេរទ្រព្យសម្បត្តិរដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រុមហ៊ុនហ្វ្រីគគ្រេដ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងកាត់ចំណីផ្លូវ ដូចខាងក្រោម÷

១. កាត់ផ្ទៃដីទំហំ ៦ ១៦១ (ប្រាំមួយពាន់មួយរយហុកសិបមួយ) ម៉ែត្រការ៉េ ជូន ឈ្មោះ តាន់ សុម៉ាលី ទទួលបានសិទ្ធិកាន់កាប់ស្របច្បាប់។

២. កាត់ផ្ទៃដីទំហំ ៣ ៧៤៨ (បីពាន់ប្រាំពីររយសែសិបប្រាំបី) ម៉ែត្រការ៉េ ជូន ឈ្មោះ តាន់ សុទ្ធារី ទទួលបានសិទ្ធិកាន់កាប់ស្របច្បាប់។

៣. កាត់ផ្ទៃដីទំហំ ១ ២៨៥ (មួយពាន់ពីររយប៉ែតសិបប្រាំ) ម៉ែត្រការ៉េជូន ឈ្មោះ ប៊ុន សុខលី ទទួលបានសិទ្ធិកាន់កាប់ស្របច្បាប់។

៤. កាត់ផ្ទៃដីទំហំ ១ ១៦០ (មួយពាន់មួយរយហុកសិប) ម៉ែត្រការ៉េ ជូនឈ្មោះ ឡុង ឡាយ ទទួលបានសិទ្ធិកាន់កាប់ស្របច្បាប់។

៥. កាត់ផ្ទៃដីធ្វើផ្លូវប្រើប្រាស់ក្នុងភូមិចំនួន ០៣ ខ្សែទំហំ ១ ៦៣៩ (មួយពាន់ប្រាំមួយរយសាមសិបប្រាំបួន)ម៉ែត្រការ៉េ។

៦. កាត់ជូនប្រជាពលរដ្ឋជាច្រើនគ្រួសារផ្សេងទៀតដែលកាន់កាប់ទំហំ ៦៩ ៧៩១ (ហុកសិបប្រាំបួនពាន់ប្រាំពីររយកៅសិបមួយ) ម៉ែត្រការ៉េ។

៧. កាត់ផ្ទៃដីចេញសម្រាប់ចំណីផ្លូវជាតិលេខ៦ ទំហំ ១ ៣៥០ (មួយពាន់បីរយហាសិប) ម៉ែត្រការ៉េ។

**មាត្រា២.-**

ផ្ទេរដីជូនការិយាល័យឧស្សាហកម្មស្រុកព្រះនេត្រព្រះ ដើម្បីកាន់កាប់ធ្វើទីតាំងផលិតទឹកស្អាតប្រើប្រាស់ក្នុងស្រុកទំហំ ១០ ០០០ (ដប់ពាន់)ម៉ែត្រការ៉េ។

**មាត្រា៣.-**

រក្សាផ្ទៃដី-ឃ្លាំងនៅសល់ទំហំ ៣ ៤១៦(បីពាន់បួនរយដប់ប្រាំមួយ) ម៉ែត្រការ៉េ ជូនក្រុមហ៊ុនហ្វ្រីគគ្រេដគ្រប់គ្រង ប្រើប្រាស់ និងចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួនឱ្យបានត្រឹមត្រូវ។

**មាត្រា៤.-**

ត្រូវបានលុបទំហំដីដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រុមហ៊ុនហ្វ្រីគគ្រេដនៃក្រសួងពាណិជ្ជកម្ម។

ត្រូវកត់ត្រាដីទំហំ ១០ ០០០ (ដប់ពាន់)ម៉ែត្រការ៉េ ចូលក្នុងបញ្ជីសារពើភណ្ឌរបស់ការិយាល័យឧស្សាហកម្មស្រុកព្រះនេត្រព្រះ។

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦ រោច ខែ អាសាឍ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ